## ការឆ្លុះមើលមហារីកសុដន់ដោយកាំរស្មីអ៊ិក

### ការឆ្លុះមើលមហារីកសុដន់ដោយកាំរស្មីអ៊ិក

ការឆ្លុះមើលមហារីកសុដន់ដោយកាំរស្មីអ៊ិក គឺជាការឆ្លុះមើលប្រចាំឆ្នាំដែលសំខាន់ សម្រាប់ស្ត្រីដែលមានអាយុ 40ឆ្នាំ និងចាស់ជាងនេះ ។ ការថតនេះគឺជា ការឆ្លុះរកមើលដុំពក ឬការប្រែប្រួលនានានៅក្នុងសុដន់ ។ វាជាតេស្តដែល មានប្រយោជន៍ ក្នុងការរកមើលជំងឺមហារីកសុដន់។

### ការរៀបចំខ្លួនមុនការទៅឆ្លុះ

- ចាត់កាលវិភាគចំពោះការទៅឆ្លុះ មួយសប្តាហ៍ក្រោយការមករដូវរបស់អ្នក ដែលគឺជាពេលមួយដែលដោះរបស់អ្នកមិនស្ពឹក ឬមិនឡើង ។
- នៅថ្ងៃឆ្លុះ មិនត្រូវលាបម្សៅតែល ប្រើថ្នាំបំបាត់ក្លិន ប្រើឡេលាបខ្លួន ឬទឹកអប់នៅបរិវេណក្លៀក ឬនៅលើបរិវេណដោះរបស់អ្នកឡើយ ។
- មិនត្រូវពាក់អាវជាប់នឹងសំពត់ ដើម្បីឱ្យងាយស្រួលដោយអ្នកគ្រាន់តែដោះអាវក្រៅ និងអាវទ្រនាប់ចេញ ដើម្បីថត ។
- ចៀសវាងពាក់គ្រឿងអលង្កា បើអ្នកពាក់ វាគួរតែជាអលង្កាដែលអាចដោះចេញបានលឿន (ជាពិសេសគឺក្រវិល ឬខ្សែក) ។



### អ្វីដែលនឹងកើតឡើង

នៅក្នុងថ្ងៃថត គិលានុប្បដ្ឋាកនឹងនាំអ្នកចូលទៅក្នុងបន្ទប់សម្រាប់ថត ។ អ្នកត្រូវដោះអាវចេញ ហើយត្រូវពាក់សម្លៀកបំពាក់អ្នកជំងឺជំនួសវិញ ។ គិលានុប្បដ្ឋាក ឬអ្នកថត នឹងសួរអ្នកពីរបីសំណួរ អំពីប្រវត្តិសុខភាពរបស់អ្នក និងកត្តាហានិភ័យចំពោះជំងឺមហារីកសុដន់ ។ អ្នកថតអាចធ្វើការពិនិត្យ ដោះរបស់អ្នក ដើម្បីរកមើលភាពខុសប្រក្រតី ដែលគួរតែថតឆ្លុះមើល ។

បន្ទាប់មក បើអាចធ្វើទៅកើត អ្នកត្រូវឈរ ដើម្បីថត ។ អ្នកត្រូវដាក់ដោះរបស់អ្នកលើឧបករណ៍សម្រាប់ថត ហើយពេលនោះនឹងមានបាញ់សម្ពាធជាជំនួយផងដែរ ។ ការថតអាចធ្វើឱ្យអ្នកមានអារម្មណ៍មិនសុខស្រួលតិចតួច តែភាពពិបាកទាំងនេះនឹងមិនលើសពីមួយនាទីឡើយ គឺកើតឡើងពេលដែលការថតកាំរស្មីអ៊ិកដំណើរការ ។



## ការតេស្តស្បូន និងការឆ្លុះត្រគាក មើលមហារីកស្បូន

ការតេស្តស្បូន និងការឆ្លុះត្រគាក គឺជាផ្នែកធំមួយ នៃជាសុខភាព ។ ការឆែកមើលជាទៀងទាត់ អាចជួយបានក្នុងការរក មើលជំងឺមហារីក ការឆ្លងជំងឺនានា និងការឆ្លងជំងឺកាមរោគ ដែលអាចព្យាបាលជាសះស្បើយបាន បើរកឃើញទាន់ពេល ។ ការតេស្តស្បូន ឆែកមើលមហារីកស្បូន និងការឆ្លុះត្រគាក ឆែកមើលសរីរាង្គបន្តពូជរបស់អ្នក ។

### របៀបរៀបចំមុនការទៅពិនិត្យ

- ពេលមករដូវ អ្នកមិនត្រូវធ្វើតេស្តមើលមហារីកស្បូនឡើយ ។
- ហាមប្រើទឹកថ្នាំលាងយោនី ឬប្រើក្រែមយោនី ថាហ្វូយ ឬហ្វូមណាមួយ ចំនួនពីរថ្ងៃមុនការធ្វើតេស្តមើលមហារីកស្បូន ។
- មិនត្រូវរួមភេទចំនួនពីរថ្ងៃមុនការធ្វើតេស្តរកមើលមហារីកស្បូន ។

### អ្វីដែលនឹងកើតឡើង

នៅក្នុងថ្ងៃធ្វើតេស្ត គិលានុប្បដ្ឋាក នឹងនាំអ្នកចូលទៅក្នុងបន្ទប់ពិនិត្យ ។ អ្នកត្រូវដោះសម្លៀកបំពាក់ចេញទាំងអស់ ហើយស្លៀកសម្លៀកបំពាក់អ្នកជំងឺជំនួសវិញ ។ គិលានុប្បដ្ឋាក នឹងវាស់សម្ពាធឈាម និងថ្លឹងទម្ងន់របស់អ្នក ។ បន្ទាប់មកគ្រូពេទ្យស្រីនឹងចូលមក ហើយសួរអ្នកពីរបីសំណួរនៅ មុនពេលធ្វើការពិនិត្យ ។ គ្រូពេទ្យនឹងចាប់ផ្តើម ដោយការពិនិត្យមើលដោះរបស់អ្នកទាំងពីរ ។

បន្ទាប់មក គ្រូពេទ្យនឹងសុំឱ្យអ្នករំកិលចុះក្រោមរហូតដល់ចុងគ្រែ ហើយដាក់ជើងទាំងពីររបស់អ្នកលើឈ្នាន់ ។



គ្រូពេទ្យ នឹងអង្គុយត្រង់ចុងជើងរបស់អ្នក ហើយសុំឱ្យអ្នកកន្ធែកជើងចេញ ។ គ្រូពេទ្យនឹងបើកអំពូលចង្កៀង ដើម្បីឆ្លុះមើលស្បូនរបស់អ្នក ។ បន្ទាប់មកគ្រូពេទ្យនឹងស៊កបរិក្ខារយ៉ាងថ្នមៗចូលទៅក្នុងរន្ធយោនីរបស់អ្នក ដើម្បីចាប់យកកោសិកាស្បូនរបស់អ្នក ។ ក្រោយពេលគ្រូពេទ្យប្រមូលកោសិកាបានរួចរាល់ហើយ គ្រូពេទ្យនឹងឆ្លុះមើលត្រគាក ដោយការស៊កម្រាម ដៃពីរចូលក្នុងរន្ធយោនីរបស់អ្នក ដើម្បីឆែកមើលតួស្បូន និងអូវែរបស់អ្នក ។ ពេលដែលការឆែកមើលបានចប់សព្វគ្រប់ហើយ អ្នកអាចស្លៀកសម្លៀកបំពាក់វិញបាន ។

**អ្នក និងគ្រួសារអ្នកត្រូវមានសុខភាពល្អ!**

## របៀបបានទទួលការពិនិត្យមហារីកដោះ និងមហារីកស្បូនដោយមិនបាច់បង់ប្រាក់

## Illinois Breast and Cervical Cancer Program (IBCCP-កម្មវិធីមហារីកដោះ និងមហារីកស្បូន រដ្ឋអ៊ីលីណយ)

កម្មវិធី IBCCP ត្រូវបានរៀបចំឡើងដោយរដ្ឋអ៊ីលីណយ ដើម្បីជួយដល់ស្រ្តីដែលមកពីគ្រួសារមានប្រាក់ចំណូលទាប ឱ្យមានឱកាសបានទទួលការពិនិត្យរកមើលជំងឺមហារីកដោះ និងមហារីកស្បូន ដោយមិនបាច់បង់ប្រាក់ រៀងរាល់ឆ្នាំ ។ ដើម្បីមានលក្ខណៈសម្បត្តិអាចទទួលការពិនិត្យ ដោយមិនបាច់បង់ប្រាក់អ្នកត្រូវតែជាស្រ្តីដែលមានអាយុពីរវាង35-64ឆ្នាំ រស់នៅក្នុងរដ្ឋអ៊ីលីណយ ប្រាក់ចំណូលតិច ហើយមិនបានទទួលការធានា រ៉ាប់រងសុខភាព ។

មានភ្នាក់ងារជាច្រើនដែលអាចជួយអ្នកបានទទួលការថតឆ្លុះមើលមហារីកដោះ និង តេស្តមើលមហារីកស្បូនដោយមិនបាច់បង់ប្រាក់ ។ បញ្ជីឈ្មោះភ្នាក់ងារដែលជាអ្នកផ្តល់សេវា ដោយប្រើភាសាផ្សេងៗនៅតំបន់ឈីកាហ្គូ មានផ្តល់ជូននៅក្នុងខិត្តប័ណ្ណ ។

## Stand Against Cancer（ការងើបឈរប្រឆាំងនឹងជំងឺមហារីក）

បន្ថែមពីលើ IBCCP ក៏មានក្រុមសម្ព័ន្ធប្រឆាំងនឹងជំងឺមហារីក ដែលហៅថា Stand Against Cancer ។ ក្រុមនេះមានផ្តល់ជូនការ ឆ្លុះដោះ រកជំងឺមហារីកដល់ស្រ្តីដែលមានអាយុច្រើនជាង 40ឆ្នាំ ។ បញ្ជីរឈ្មោះគ្លីនិកដែលផ្តល់សេវាដល់អ្នកជំងឺនិយាយភាសាអារ៉ាប់  មានផ្តល់ជូននៅក្នុង ខិត្តប័ណ្ណ ។ អ្នកក៏អាចហៅទូរស័ព្ទទៅកាន់គ្លីនិកទាំងនោះបាន ដើម្បី រកមើលគ្លីនិកដែលនៅក្បែរអ្នកដែលផ្តល់សេវាដល់អ្នកជំងឺដោយ ប្រើភាសាផ្សេងទៀត ។

សម្រាប់ជំនួយបន្ថែម សូមទំនាក់ទំនងមកកាន់ :

**Chinese Mutual Aid Association**
1016 West Argyle Street
Chicago, IL 60640-3715
(773) 784-2900

**Cambodian Association of Illinois**
2831 W Lawrence Ave
Chicago, IL 60625-3619
(773) 878-7090

**Vietnamese Association of Illinois**
5110 N Broadway St
Chicago, IL 60640-3004
(773) 728-3700

**IBCCP (1-888-522-1282)**

Asian Human Services
（សេវាបំរើជនអាស៊ី）
2424 W. Peterson, Chicago, IL  60659
ទូរស័ព្ទ : 773-761-0011

Uptown Clinic（គ្លីនិក Uptown）
845 W. Wilson, Chicago, IL
ទូរស័ព្ទ : 312-744-2146

Mercy Hospital（មន្ទីរពេទ្យនៃក្តីអាណិត）
2525 S. Michigan Ave, Chicago, IL 60616
ទូរស័ព្ទ : 312-567-2619

**Stand Against Cancer (1-888-722-4673)**

ACCESS Evanston and Rogers Park
（ACCESS Evanston និងសួន Rogers）
1555 W. Howard, Chicago, IL
ទូរស័ព្ទ : 773-764-7146

318 W. Madison St., Maywood, IL
ទូរស័ព្ទ : 708-344-5300

556 E. 115th St., Chicago, IL
ទូរស័ព្ទ : 773-785-6800

Asian Health Coalition（សម្ព័ន្ធសុខភាពជនអាស៊ី） គឺជាអង្គការក្រោមមាត្រាច្បាប់ 501c(3) មិនរកកំរៃ ដែលបានបង្កើតឡើងក្នុងឆ្នាំ 1996 ដែលមានបេសកកម្មដើម្បីលើកកំពស់សុខភាព និងសុខុមាលភាពនៃសហគមន៏អាមេរិកាំងដើមកំណើតអាស៊ី តាមរយៈការតស៊ូមតិ ជំនួយបច្ចេកទេសការអប់រំសាធារណៈ និងសហគមន៏ ព្រមទាំងការសិក្សាស្រាវជ្រាវ ។ ដើម្បីបានដឹងព័ត៌មានបន្ថែម សូមទស្សនាគេហទំព័រ www.asianhealth.org.

# ASIAN HEALTH COALITION



## ការថតឆ្លុះមើលជំងឺមហារីកដោះ និងជំងឺមហារីកស្បូន ដោយមិនបាច់បង់ប្រាក់

**ដៃគូ :**

**Chinese Mutual Aid Association**

**Cambodian Association of Illinois**

**Vietnamese Association of Illinois**